**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៦៩ ព.ណ.ជណ.ប្រក

# ប្រកាស
## ស្តីពី
## របៀបរបបការងារ និងការបែងចែកភារកិច្ច
## របស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៧ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ ស្ទួន នៃអនុក្រឹតលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឲ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១៖** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ចជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទទួលខុសត្រូវ និងដឹកនាំកិច្ចការទូទៅរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ ២៖** រដ្ឋមន្ត្រី ជាប្រធានស្ថាប័នទទួលខុសត្រូវដឹកនាំការងាររួមរបស់ក្រសួងពាណិជ្ជកម្ម ជាពិសេសដឹកនាំត្រួតពិនិត្យ និងតាមដានការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ច របស់ក្រសួងពាណិជ្ជកម្ម និងដោយឡែកដឹកនាំគ្រប់គ្រង៖

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- នាយកដ្ឋានបុគ្គលិក នាយកដ្ឋាននាំចេញ-នាំចូល អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហារណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ក្រុមហ៊ុនហ្រ្វីនត្រេដ តំណាងពាណិជ្ជកម្មក្រៅប្រទេស និងតំណាងពាណិជ្ជកម្មប្រចាំតំបន់សេដ្ឋកិច្ចពិសេស
- ពិនិត្យតាមដានរាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រធានក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម។

**ប្រការ ៣** ៖ ត្រូវបានបែងចែកភារកិច្ចជូនរដ្ឋលេខាធិការ ដើម្បីជួយរដ្ឋមន្ត្រី ដូចខាងក្រោម ៖

១. ឯកឧត្តម **កឹម ស៊ីថន** និងឯកឧត្តម **សុខ សុភ័ក្ត្រ** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់
- មន្ទីរពាណិជ្ជកម្មខេត្តកោះកុង មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ ពាណិជ្ជកម្មខេត្តកំពត
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងគណៈកម្មាធិការជាតិភស្តុភារកម្ម
- ប្រធានក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងពាណិជ្ជកម្ម
- ក្រុមការងារផ្នែកថាមពល-ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន
- កិច្ចសហប្រតិបត្តិការតំបន់ និងអនុតំបន់៖ តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម តំបន់មរតកកម្ពុជា-ឡាវ-ថៃ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្រុមប្រឹក្សាជាតិស្ថិតិ
- គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពាណិជ្ជកម្មអន្តរជាតិ៖ ពាណិជ្ជកម្មទ្វេភាគី ពហុភាគី ពាណិជ្ជកម្មកម្ពុជា-សហគមន៍អឺរ៉ុប និងអង្គការពាណិជ្ជកម្មពិភពលោក
- ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម សហព័ន្ធស្រូវអង្ករកម្ពុជា
- ក្រុមការងារផ្នែកស្រូវ-អង្ករ។

២. ឯកឧត្តម **ឱក ប៊ុន** និងឯកឧត្តម **រាជ រ៉ា** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ និងនាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទ្វីបទៅអាមេរិក
- ពិនិត្យតាមដានផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា
- គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ
- គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ។

៣. ឯកឧត្តម **ម៉ៅ ថូរ៉ា** ឯកឧត្តម **ទេ៉ង សុធី** ឯកឧត្តម **សាន់ សារ៉េន** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋាននីតិកម្ម នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

- មន្ទីរពាណិជ្ជកម្មខេត្តក្រចេះ មន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែង មន្ទីរពាណិជ្ជកម្មខេត្តរតនគិរី និងមន្ទីរពាណិជ្ជកម្មខេត្តមណ្ឌលគិរី
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការពារជាតិ ក្រសួងផែនការ ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អង្គភាពប្រឆាំងអំពើពុករលួយ
- សភាពាណិជ្ជកម្មកម្ពុជា
- គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- ក្រុមប្រឹក្សាកសិកម្ម និងអភិវឌ្ឍន៍។

៤. ឯកឧត្តម **ឈួន ដារ៉ា** និងឯកឧត្តម **សំ សិរីរតន៍** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានកិច្ចការពិពរណ៍ និងនាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ
- មន្ទីរពាណិជ្ជកម្មខេត្តកណ្ដាល មន្ទីរពាណិជ្ជកម្មខេត្តតាកែវ មន្ទីរពាណិជ្ជកម្មព្រៃវែង និងមន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ
- គណៈកម្មាធិការរៀបចំផែនការ កិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវសូត្រ និងផ្លូវសូត្រសមុទ្រសតវត្សទី២១
- ក្រុមការងារសកម្មភាពជនពិការ
- ក្រុមការងារផ្នែកទេសចរណ៍។

៥. ឯកឧត្តម **អ៊ុក ប្រជា** និងឯកឧត្តម **ភឹម សុខុន** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង មន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ មន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងរ៉ែ និងថាមពល និងក្រសួងបរិស្ថាន
- ក្រុមប្រឹក្សាជាតិកម្មសិទ្ធិបញ្ញា
- ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូច មធ្យម
- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច
- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន។

៦. លោកជំទាវ **តឹករ៉េត កំរេខ** និងលោកជំទាវ **ចម និម្មល** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានអាមេរិក
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអាស៊ីប៉ាស៊ីហ្វិក
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប និងមន្ទីរពាណិជ្ជកម្មខេត្តកែប
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងសុខាភិបាល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងកិច្ចការនារី

- គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) និងពាណិជ្ជកម្មទ្វេភាគី ពហុភាគី
- គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់។

៧. ឯកឧត្តម **ឃឹម សិរីវឌ្ឍ** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានរដ្ឋបាល
- មន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ និងមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងមុខងារសាធារណៈ ក្រសួងព័ត៌មាន
- ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ
- ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី-ខេត្ត។

៨. ឯកឧត្តម **ប៉ាវ ហេងតារា** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- មន្ទីរពាណិជ្ជកម្មខេត្តពោធិ៍សាត់ មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង និងមន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងធម្មការ និងសាសនា

  ធនាគារជាតិនៃកម្ពុជា
- ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ។

៩. ឯកឧត្តម **ស៊ុន ដារ៉ាវឌ្ឍ** មានភារកិច្ចជួយរដ្ឋមន្ត្រីលើការងារ ៖
- ទទួលបន្ទុកជានាយកខុទ្ទកាល័យ ឯកឧត្តមរដ្ឋមន្ត្រី និងសម្របសម្រួលការងារក្នុងក្រសួងពាណិជ្ជកម្ម។

**ប្រការ ៤៖** ត្រូវបានបែងចែកភារកិច្ចជូនអនុរដ្ឋលេខាធិការ ដូចខាងក្រោម៖

១- ឯកឧត្តម **ពេជ ឫទ្ធី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **គីម ស៊ីថន** និងលោកជំទាវ **តឹករ៉េត កំរេង**

២- លោកជំទាវ **សូ ស្រីមុិច** ទទួលភារកិច្ចជួយការងារ លោកជំទាវ **តឹករ៉េត កំរេង** និង ឯកឧត្តម **ឃឹម សិរីវឌ្ឍ**

៣- ឯកឧត្តម **ចាន់ រ៉ាស៊ី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឱក ប៊ុង** និងឯកឧត្តម **ម៉ៅ ថូរ៉ា** និងមានភារកិច្ចជួយការងារពាក់ព័ន្ធ៖
- ក្រុមការងារអន្តរក្រសួងទទួលបន្ទុកកិច្ចការ សរសេររបាយការណ៍ជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ជូនអង្គការសហប្រជាជាតិ។

៤- ឯកឧត្តម **ម៉ក់ ឧសភា** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឱក ប៊ុង** និងលោកជំទាវ **ចម និម្មល** និងមានភារកិច្ចជួយការងារពាក់ព័ន្ធ៖
- ការងារសម្របសម្រួលជាមួយអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្រ្កាបការក្លែងបន្លំ (កាំកុងត្រូល)។

៥- ឯកឧត្តម **សំហេង បូរ៉ា** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **អ៊ុក ប្រជា** និងលោកជំទាវ **ចម និម្មល**

៦- ឯកឧត្តម **ឡុស់ វ៉ូហ្សាក់** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឈួន ដារ៉ា** និងឯកឧត្តម **សាន់ សារ៉េន**

៧- ឯកឧត្តម **ប៊ុន ចន្ធី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **សុខ សុភ័ក្រ្ត** និងឯកឧត្តម **ប៉ាវ ហេងតារា**

៨- ឯកឧត្តម **ស៊ឹម សុខខេង** ឯកឧត្តម **ប៉ែន សុវិជាតិ** ទទួលភារកិច្ចជួយការងារ លោកជំទាវ **តឹករ៉េត កំរេង** និងឯកឧត្តម **សុខ សុភ័ក្រ្ត**

៩- ឯកឧត្តម **ស៊ាង ថៃ** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឈួន ដារ៉ា** និងឯកឧត្តម **សំ សិរីរតន៍**

១០- ឯកឧត្តម **ថៅ សុខមុនី** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ឱក ប៊ុច** និងឯកឧត្តម **ម៉ៅ ថូរ៉ា**

១១- លោកជំទាវ **ប៊ុន ណារ៉ាត** ទទួលភារកិច្ចជួយការងារ លោកជំទាវ **តឹករ៉េត តំរេខ** និង លោកជំទាវ **ចម និម្មល**

១២- ឯកឧត្តម **ចាន់ ហ៊ីច** ទទួលភារកិច្ចជួយការងារ ឯកឧត្តម **ទេីច សុធី** និងឯកឧត្តម **ឃឹម សិរីវឌ្ឍ**។

**ប្រការ ៥** ៖ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មានភារកិច្ចអនុវត្តការងារផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ ៦** ៖ ការកំណត់របៀបរបបការងារ ៖

១- រដ្ឋមន្ត្រី ពិនិត្យសម្រេច និងចុះហត្ថលេខាលើរាល់ឯកសារមានដូចជា៖ ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំ បង្គាប់ការ និងឯកសារដែលត្រូវផ្ញើជូនប្រមុខរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ឬស្ថាប័នកំពូលផ្សេងទៀត។

២- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ទទួលខុសត្រូវ និងពិនិត្យតាមចង្កោមការងារទទួលបន្ទុក ដែលបានប្រគល់ជូន និងផ្តល់យោបល់ជូនរដ្ឋមន្ត្រី ពិនិត្យ សម្រេចលើរាល់សំណើដែលមានការពាក់ព័ន្ធ។

៣- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ ត្រូវទទួលខុសត្រូវ និងពិនិត្យ ផ្តល់យោបល់ជូនរដ្ឋលេខាធិការ នូវការងារដែលស្ថិតនៅក្នុងចង្កោម ការងាររបស់ខ្លួន។

**ប្រការ ៧** ៖ ការកំណត់របបប្រជុំ ៖

ក- ប្រជុំប្រចាំសប្តាហ៍ ៖ ធ្វើឡើងនៅថ្ងៃពុធ ឬតាមការចាំបាច់ ដោយមានការចូលរួមពី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក-អគ្គនាយករង អគ្គាធិការ-អគ្គាធិការរង អគ្គនាយក-អគ្គនាយករងកាំកុងត្រូល អគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ ប្រធាន-អនុប្រធាននាយកដ្ឋាន និងប្រធាន-អនុប្រធានអង្គភាពចំណុះក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល ដើម្បីស្តាប់របាយការណ៍ ពិភាក្សា ដោះស្រាយការងាររួម និងកែលម្អចំណុចខ្វះខាត។

ខ- ប្រជុំប្រចាំខែ ៖ ធ្វើឡើងនៅថ្ងៃពុធ សប្តាហ៍ទីបួននៃខែនីមួយៗ ដោយមានការចូលរួមពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង អគ្គនាយក អគ្គនាយករង កាំកុងត្រូល អគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ ប្រធាន-អនុប្រធាននាយកដ្ឋាន និងប្រធាន-អនុប្រធានអង្គភាពចំណុះក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដើម្បីស្តាប់របាយការណ៍ ពិភាក្សា និងដោះស្រាយការងាររួម និងកែលម្អចំណុចខ្វះខាត។

គ- ប្រជុំថ្នាក់អគ្គនាយកដ្ឋាន ៖ នៅរៀងរាល់ខែនីមួយៗ អគ្គនាយកដ្ឋាន អគ្គនាយកដ្ឋានកាំកុងត្រូល អគ្គាធិការដ្ឋាន និងក្រុមហ៊ុនហ្គ្រីនត្រេដ ត្រូវរៀបចំឲ្យមានការប្រជុំប្រចាំខែ ដើម្បីបូកសរុបអំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ លើកវិធានការដោះស្រាយ និងកំណត់ទិសដៅការងារដែលត្រូវធ្វើបន្ត។

ឃ- ប្រជុំថ្នាក់នាយកដ្ឋាន ៖ នៅរៀងរាល់ពីរសប្តាហ៍ម្តង នាយកដ្ឋានត្រូវរៀបចំឲ្យមានការប្រជុំផ្ទៃក្នុងនាយកដ្ឋានរបស់ខ្លួននីមួយៗ ដើម្បីតាមដានការងាររបស់អង្គភាព។

ង- ប្រជុំថ្នាក់មន្ទីរពាណិជ្ជកម្ម ៖ នៅរៀងរាល់ខែនីមួយៗ មន្ទីរត្រូវរៀបចំឲ្យមានការប្រជុំផ្ទៃក្នុងមន្ទីររបស់ខ្លួននីមួយៗ ដើម្បីតាមដានការងាររបស់មន្ទីរ។

ច- រាល់កិច្ចប្រជុំត្រូវមានរបាយការណ៍ ឬកំណត់ហេតុអង្គប្រជុំ។

**ប្រការ ៨** ៖ ប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ក.

**ប្រការ ៩ ៖** នាយកខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ដែលមានឈ្មោះក្នុងប្រការ៣ និងប្រការ៤ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២ កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**<u>ចម្លងជូន៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ